ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខ...០០៤...សសរ.../គ.ជ.អ.ប

រាជធានីភ្នំពេញ ថ្ងៃទី...២៨... ខែ........ឆ្នាំ២០១២

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឲ្យប្រើប្រាស់នូវសេចក្តីណែនាំស្តីពីការរៀបចំបញ្ជីឯកសារបស់ក្រសួង ស្ថាប័នមន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៣០១/០៥ចុះថ្ងៃទី១៩ខែមីនាឆ្នាំ២០០១ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៧ចុះថ្ងៃទី២២ខែឧសភាឆ្នាំ២០០៨ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុងស្រុកខណ្ឌ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១១/០១១ចុះថ្ងៃទី១៧ខែមិថុនាឆ្នាំ២០១១ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២០៨/១៤២៥ចុះថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៨ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៣ មាត្រា១៥ មាត្រា១៦ និងមាត្រា១៧ នៃអនុ



វិថីព្រះនរោត្តម: លេខាធិការដ្ឋាននៃគ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ: (៨៥៥-២៣) ៧២០ ០៦១/ ៧២០ ០៣៨ E-mail: info@ncdd.gov.kh Website: www.ncdd.gov.kh
... Blvd. National Committee for Sub-National Democratic Development Secretariat (NCDDS), Ministry of Interior. Tel: (855-23) 720 061 / 720 038

ក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ៣៦អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក
- បានឃើញអនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី១០ខែឧសភាឆ្នាំ២០១២ ស្ដីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងកិច្ចប្រជុំលើកទី៧ នាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១២។

## សម្រេច

**ប្រការ ១.-**

ដាក់ឲ្យប្រើប្រាស់នូវ "**សេចក្ដីណែនាំស្ដីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័នមន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់**"។

**ប្រការ ២.-**

ក្រសួង ស្ថាប័ន មន្ទីរអង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវប្រើប្រាស់សេចក្ដីណែនាំនេះធ្វើជាមូលដ្ឋានក្នុងការរៀបចំបញ្ជីវិភាគមុខងាររបស់ខ្លួន ដូចបានកំណត់ក្នុងអនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី១០ខែឧសភាឆ្នាំ២០១២ ស្ដីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ ៣.-**

សេចក្ដីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ជ.គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ**
**តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**
**ប្រធាន**

ស ខេង

**ចម្លងជូន៖**
- *ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប*
- *ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*

*"ដើម្បីអនុវត្ត"*
- *ឯកសារកាលប្បវត្តិ*